រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ១៩៩៤

# សេចក្តីសំរេចលេខ ៧៤ សសរ
# ស្តីពីការបង្កើតគណៈកម្មការពិសេស អង្កេតមជ្ឈមណ្ឌល ឃុំឃាំង សម្ងាត់របស់កងយោធពលខេមរភូមិន្ទនៅខេត្តបាត់ដំបង
# រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .

-តាមសំណើរបស់ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សំរេច

ប្រការ ១: បង្កើតគណៈកម្មការពិសេស អង្កេតមជ្ឈមណ្ឌលឃុំឃាំងសម្ងាត់ របស់កងយោធពលខេមរភូមិន្ទនៅ ខេត្តបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ៣-តំណាងក្រសួងការពារជាតិ | សមាជិក |
| ៤-តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៥-តំណាងខេត្តបាត់ដំបង | សមាជិក |

ប្រការ ២ : គណៈកម្មការពិសេសនេះ មានភារកិច្ចធ្វើការស្រាវជ្រាវស៊ើបអង្កេតជាបន្ទាន់ អំពីទីតាំងរបស់មជ្ឈមណ្ឌលឃុំឃាំង និង សកម្មភាពនានាដែលមជ្ឈមណ្ឌលបានអនុវត្តរំលោភបំពានទៅលើពិរុទ្ធជន ។

-បូកសរុបលទ្ធផល នៃការស្រាវជ្រាវ ដើម្បីរាយការណ៍ជូនគណៈរដ្ឋមន្ត្រីអោយបានមុនថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ១៩៩៤ ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបងត្រូវអនុវត្តតាមសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| --- | --- |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

• • •

រាជធានីភ្នំពេញ ,ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៤

## សេចក្តីសំរេចលេខ ៧៥ សសរ-សរ

## ស្តីពីការផ្ទេរសិទ្ធិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៦ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- យោងតាមការងារចាំបាច់